នីកជញ្ជូន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អភិបាលក្រុងព្រះសីហនុ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងឯកឧត្តមដែលមានរាយនាមក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៩

## សេចក្តីសម្រេចលេខ ៥៨ សសរ
## ស្តីពីការតែងតាំងទីប្រឹក្សានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

### សម្រេច

ប្រការ ១ : តែងតាំងលោកឧកញ៉ា ឡូស្មាន ហាស្សាន់ ជាទីប្រឹក្សាសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : លោកឧកញ៉ា ឡូស្មាន ហាស្សាន់ ត្រូវអនុវត្តនូវសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩

## សេចក្តីសម្រេចលេខ ៥៩ សសរ
## ស្តីពីការផ្ទេរសិទ្ធិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតំរូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

ប្រការ ១ : ប្រគល់សិទ្ធិជូន ឯកឧត្តម អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ទទួលបន្ទុកបន្ថែម ជារដ្ឋមន្ត្រីស្តីទី នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជំនួស ឯកឧត្តម ហោ ណាំហុង ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ដោយគិតចាប់ពីថ្ងៃទី២៨ ខែសីហា រហូតដល់ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៩៩ ខាងមុខនេះ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នប្រតិភូរាជរដ្ឋាភិបាល អភិបាល ខេត្ត-ក្រុង និង ឯកឧត្តម អ៊ឹម ឈុនលឹម ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

★★★

## ៣-ផែនការណែនាំ

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩

### ផែនការណែនាំលេខ ១១ ផកណ

**ស្តីពីការរៀបចំពិធីបុណ្យគ្រងរាជសម្បត្តិជាថ្មីរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងប្រកាសវេជ្ជធម្មនុញ្ញ និងពិធីបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ**

***

* ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៩ ខាងមុខនេះ គឺជាបុណ្យខួបលើកទី៦ នៃការគ្រងរាជសម្បត្តិជាថ្មី របស់ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង